ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ១២.០១៨.១២១.១.របក

ថ្ងៃ ចន្ទ ១៣ រោច ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨

## ជម្រាបមក
## លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា នៃបុគ្គលរាយការណ៍ទាំងអស់

**កម្មវត្ថុ៖** របាយការណ៍លទ្ធផលសង្ខេបស្តីពីការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

**យោង ៖**
- ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧
- ប្រកាសលេខ ធ៧.០៨.០៨៩ ប្រ.ក. ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ប្រកាសលេខ ធ១២.០១០.២០៦ ប្រ.ក. ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី អគ្គនាយក អគ្គនាយិកាទាំងអស់ ជ្រាបថា ប្រទេសកម្ពុជាបានអនុវត្តការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដោយបានពិនិត្យឃើញពីកម្រិតហានិភ័យថ្នាក់ជាតិ និងនៅតាមវិស័យពាក់ព័ន្ធនានា។ ដូចនេះ ស.ហ.ក សូមផ្តល់របាយការណ៍លទ្ធផលសង្ខេបស្តីពីការវាយតម្លៃហានិភ័យថ្នាក់ជាតិនេះដូចមានភ្ជាប់មកជាមួយ ជូនលោក លោកស្រី អគ្គនាយក អគ្គនាយិកា ដើម្បីបញ្ចូលទៅក្នុងដំណើរការវាយតម្លៃហានិភ័យរបស់គ្រឹះស្ថាននិងធ្វើជាមូលដ្ឋានក្នុងការអនុវត្តវិធានការនានា ស្របតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា អនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ទទួលនូវការរាប់អានអំពីខ្ញុំ។

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**
**អគ្គលេខាធិការ**

ស.ហ.ក

**សាយ សំអាត**